01095297

E335/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 05 / 2015
ម៉ោង (Time/Heure): 15:40
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **យ៉ា សុខន**
ចៅក្រម Claudia FENZ
ចៅក្រម **យូរ ឧត្តរា**

កាលបរិច្ឆេទ: ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥

ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

---

# សេចក្តីសម្រេចទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព

---

**សហព្រះរាជអាជ្ញា**
ជា លាង
Nicolas KOUMJIAN

**ជនជាប់ចោទ**
នួន ជា
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Marie GUIRAUD

**មេធាវីជនជាប់ចោទ**
សុន អរុណ
Victor KOPPE
គង់ សំអុន
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះបានទទួលសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព ("សំណើរបស់ កសព")[1]។ មេធាវីការពារក្តី នួន ជា យល់ស្របនឹងសំណើនេះមួយផ្នែក ដោយស្នើសុំឱ្យស្តាប់សក្ខីកម្ម Rob LEMKIN ជាមួយនឹងសក្ខីកម្ម ថេត សម្បត្តិ ("ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា")[2]។

## ២. សារណា

២. សហព្រះរាជអាជ្ញាលើកឡើងថា នៅក្នុងខ្សែភាពយន្ត និង នៅក្នុងសៀវភៅរបស់គាត់ លោក ថេត សម្បត្តិ បានកត់ត្រាការសារភាពមួយចំនួនរបស់ នួន ជា ដែលបង្ហាញពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទរូបនេះ ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[3]។ សហព្រះរាជអាជ្ញាលើកឡើងថា ដោយសារតែសាក្សីរូបនេះមានសារៈសំខាន់ ហើយគាត់ធ្លាប់បានបដិសេធមិន សហការជាមួយ អ.វ.ត.ក នាពេលកន្លងមក អង្គជំនុំជម្រះគួរកោះហៅគាត់ឱ្យមកផ្តល់សក្ខីកម្មឱ្យបានឆាប់ នៅពេលដែលសាក្សីរូបនេះនៅតែមានឆន្ទៈមកផ្តល់សក្ខីកម្ម[4]។

៣. សហព្រះរាជអាជ្ញាក៏បានកត់សម្គាល់ទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំកោះកៅហៅ លោក ថេត សម្បត្តិ នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ដែលជាផ្នែកមួយនៃកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខនៅក្នុងសំណុំរឿង ០០២/០១ ដែលសហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើសុំនេះ[5]។

៤. មេធាវីការពារក្តី នួន ជា យល់ស្របជាមួយសហព្រះរាជអាជ្ញាដែលថា ត្រូវពន្លឿនការស្តាប់សក្ខីកម្មលោក ថេត សម្បត្តិ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[6]។ យ៉ាងណាក៏ដោយ មេធាវី

---

[1] សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព ឯកសារ E335 ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥។

[2] ចម្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព ឯកសារ E335/1 ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥។

[3] សំណើរបស់ កសព កថាខណ្ឌ ១។

[4] សំណើរបស់ កសព កថាខណ្ឌ ៣ ដល់ កថាខណ្ឌ ៤។

[5] សំណើរបស់ កសព កថាខណ្ឌ ៥។

[6] សំណើរបស់ កសព កថាខណ្ឌ ២។

ការពារក្តីជំទាស់ទៅនឹងពេលវេលានៃការផ្តល់សក្ខីកម្ម ដោយមេធាវីស្នើឡើងថា លោក ថេត សម្បត្តិ គួរផ្តល់សក្ខីកម្មភ្លាមៗមុន ឬ ក្រោយការផ្តល់សក្ខីកម្មរបស់គាត់នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល[7]។ មេធាវីការពារក្តីលើកឡើងថា ការតម្រូវឱ្យសាក្សីធ្វើដំណើរមកប្រទេសកម្ពុជាពីរដងជាបន្តបន្ទាប់ក្នុងចន្លោះពេលខ្លីនោះ គឺជាការដាក់បន្ទុកដោយមិនត្រឹមត្រូវចំពោះសាក្សីរូបនេះ[8]។

៥. មេធាវីការពារក្តី នួន ជា បានស្នើបន្ថែមទៀតឱ្យអង្គជំនុំជម្រះសាលាដំបូងពន្លឿនការស្តាប់សក្ខីកម្មរបស់លោក Rob LEMKIN ជាមួយនឹងសក្ខីកម្មលោក ថេត សម្បត្តិ។ មេធាវីលើកឡើងថា លោក Rob LEMKIN គឺជាសាក្សីសំខាន់គន្លឹះមួយរូប ដែលអាចផ្តល់សក្ខីកម្មទៅលើអង្គហេតុដូចគ្នានឹងសក្ខីកម្មលោក ថេត សម្បត្តិ ដែរ ហើយនឹងអាចផ្តល់ភស្តុតាងបន្ថែមទៀតផងដែរ[9]។ មេធាវីការពារក្តីបានលើកឡើងថា ដោយសារតែទំនាក់ទំនងរវាងសាក្សីទាំងពីររូបនេះ ការស្តាប់សក្ខីកម្មរបស់លោក Rob LEMKIN គួរតែធ្វើឡើងនៅពេលមុនបន្តិច ឬ ក្រោយសក្ខីកម្មរបស់លោក ថេត សម្បត្តិ តែម្តង[10]។

៦. សហព្រះរាជអាជ្ញាបានឆ្លើយតបរួចហើយកាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥[11]។

## ៣. ច្បាប់ជាធរមាន និង សំអាងហេតុ

៧. អង្គជំនុំជម្រះសាលាដំបូងរម្លឹកថា អង្គជំនុំជម្រះមានឆន្ទានុសិទ្ធិក្នុងការស្តាប់សក្ខីកម្មសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញ ទៅតាមលំដាប់លំដោយដែលខ្លួនយល់ថាមានប្រយោជន៍[12]។ អង្គជំនុំជម្រះសាលាដំបូងរម្លឹកបន្ថែមទៀតថា អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង អង្គជំនុំ-ជម្រះអាចបដិសេធមិនស្តាប់ភស្តុតាង ដែល (ក) មិនជាប់ពាក់ព័ន្ធ ឬជាការស្នើសុំជាន់គ្នា (ខ) មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ (គ) មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុជាគោលដៅនៃ

---

[7] ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ៣។

[8] ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ៣។

[9] ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ៥។

[10] ចម្លើយតបរបស់មេធាវីការពារក្តី នួន ជា កថាខណ្ឌ ៥។

[11] ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ទៅនឹងសំណើសុំឱ្យកោះហៅ ថេត សម្បត្តិ ជាសាក្សីអាទិភាព ឯកសារ E335/2 ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៥។

[12] វិធាន ៨១ នៃវិធានផ្ទៃក្នុង។

ការស្នើសុំពិនិត្យភស្តុតាង (ឃ) ច្បាប់មិនអនុញ្ញាត ឬ (ង) មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬ គ្មានប្រយោជន៍[13]។

៨. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ថា បើទោះជាលោក ថេត សម្បត្តិ ត្រូវបានសហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា ស្នើឡើងជាសាក្សីម្នាក់សម្រាប់សំណុំរឿង ០០២/០១ ក៏ដោយ ក៏លោក ថេត សម្បត្តិ មិនបានឆ្លើយតបទៅនឹងការព្យាយាមទាក់ទងរបស់អង្គជំនុំជម្រះទៅគាត់នៅក្នុងសំណុំរឿងនោះដែរ[14]។ ភាគីទាំងពីរបានស្នើឡើងជាថ្មីម្តងទៀតឲ្យលោក ថេត សម្បត្តិ ធ្វើជាសាក្សីសម្រាប់សំណុំរឿង ០០២/០២ នេះ។

៩. អង្គជំនុំជម្រះយល់ឃើញថា ភស្តុតាងរបស់លោក ថេត សម្បត្តិ អាចជួយដល់ការបញ្ជាក់ការពិតពាក់ព័ន្ធនឹងបញ្ហាផ្សេងៗដែលសហព្រះរាជអាជ្ញា និង មេធាវីការពារក្តី នួន ជា លើកឡើងនៅក្នុងសំណើរបស់ពួកគាត់។ បើទោះជាសក្ខីកម្មលោក ថេត សម្បត្តិ ពាក់ព័ន្ធខ្លាំងបំផុតទៅនឹងអង្គហេតុដែលត្រូវបានគ្រោងសម្រាប់ពេលក្រោយៗនៅក្នុងសំណុំរឿង ០០២/០២ ក៏ដោយ ក៏អង្គជំនុំជម្រះយល់ឃើញថា ជាការសមស្របដែលត្រូវស្តាប់សក្ខីកម្មរបស់លោក ថេត សម្បត្តិ ក្នុងអំឡុងពេលពិនិត្យលើអង្គហេតុដំបូងៗ ប្រសិនបើគាត់ អាចចូលរួមបាននោះ។

១០. ដូចដែលបានកត់សម្គាល់ខាងលើ អង្គជំនុំជម្រះតុលាការកំពូលបានទទួលសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យកោះហៅលោក ថេត សម្បត្តិ និង Rob LEMKIN នៅក្នុងបណ្តឹងសាទុក្ខសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឱ្យស៊ើបអង្កេត អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង ដើម្បីបញ្ជាក់ថាតើឃ្លតខ្សែវីដេអូផ្សេងទៀតដែលលោក ថេត សម្បត្តិ ឬ Rob

---

[13] វិធាន ៨៧(៣) និង ៨៧ (៤) នៃវិធានផ្ទៃក្នុង។ *សូមមើលផងដែរ* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងលើ *កាំង ហ្គេកអ៊ាវ ហៅ ឌុច* ឯកសារ E188 ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១០ កថាខណ្ឌ ៤១។ *រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karemera និងអ្នកដទៃទៀត* សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ Mathieu Ngirumpatse ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៨ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR (ICTR-98-44-AR73.14) ថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០០៩ កថាខណ្ឌ ២៥ (សម្រេចថា ភាពជាន់គ្នានៃសក្ខីកម្មនឹងត្រូវចាត់ទុកជាកត្តាមួយក្នុងការកំណត់ថាតើចាំបាច់ត្រូវស្តាប់សក្ខីកម្មដែរ ឬទេ)។

[14] អនុស្សរណៈអន្តរការិយាល័យដែលមានចំណងជើងថា "សាក្សីសក្តានុពល - មិនអាចរកឃើញ" ឯកសារ E292/1/2 ថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០១៣។

LEMKIN មាន អាចទទួលបាននៅក្នុងពេលមួយសមស្របដែរ ឬទេ[15]។ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាទៅលើព័ត៌មានណាមួយដែលទទួលបានពីការស៊ើបអង្កេតនេះ ដើម្បីធ្វើការវាយតម្លៃចុងក្រោយពាក់ព័ន្ធនឹងចំណុចថាតើត្រូវកោះហៅលោក Rob LEMKIN មកផ្តល់សក្ខីកម្មដែរ ឬ យ៉ាងណា។

១១. នាពេលនេះ អង្គជំនុំជម្រះតុលាការកំពូលមិនទាន់កំណត់កាលបរិច្ឆេទសម្រាប់សវនាការទៅលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ហើយក៏មិនទាន់បានសម្រេចឯកភាពតាមសំណើរបស់មេធាវីការពារក្តីសុំឱ្យកោះហៅលោក ថេត សម្បត្តិ ឬ លោក Rob LEMKIN នៅឡើយទេ។ លើសពីនេះទៀត អង្គភាពគាំពារការការពារក្តីមិនទាន់បានទទួលការឆ្លើយតបពីលោក ថេត សម្បត្តិ ដើម្បីដឹងថាគាត់អាចចូលរួម និង មានឆន្ទៈក្នុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែរ ឬ យ៉ាងណា។ ហេតុដូច្នេះ វាហាក់ដូចជាឆាប់ពេកនៅពេលនេះក្នុងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មជាអាទិភាពរបស់ លោក ថេត សម្បត្តិ នៅចំពោះមុខអង្គជំនុំជម្រះផ្សេងៗ នៃ អ.វ.ត.ក ។

**ដោយផ្អែកលើសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង**

**ឯកភាព** តាមសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅលោក ថេត សម្បត្តិ និង **បង្គាប់** ឱ្យអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ទាក់ទងលោក ថេត សម្បត្តិ និង រាយការណ៍មកអង្គជំនុំជម្រះយ៉ាងយូរបំផុតត្រឹមថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥ អំពីលទ្ធភាពរបស់គាត់ក្នុងការចូលរួមផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។

**ពន្យារពេល** សម្រេចទៅលើសំណើរបស់មេធាវីការពារក្តី នួន ជា សុំឱ្យកោះហៅលោក Rob LEMKIN។

ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០១៥

ប្រធានអង្គជំនុំជម្រះសាលាដំបូង

**និល ណុន**

---

[15] សេចក្តីសម្រេចបណ្តោះអាសន្នលើផ្នែកខ្លះនៃសំណើទីមួយរបស់ នួន ជា សុំឱ្យអង្គជំនុំជម្រះពិចារណាទៅលើភស្តុតាងបន្ថែមទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ ឯកសារ F2/4/3 ថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៥។